**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No:៧៣៦ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការវាយតម្លៃ និងជ្រើសរើសសេវាពិគ្រោះយោបល់ ក្នុងក្របខ័ណ្ឌនៃគំរោងកិច្ចសំរួលពាណិជ្ជកម្ម និងការប្រកួតប្រជែង

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធានអនុគណៈកម្មការអចិន្ត្រៃយ៍កិច្ចសំរួលពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ រៀបចំ និង ប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- យោងសេចក្តីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើត គណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- យោងសេចក្តីសំរេចលេខ ៤៦ សសរ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើត អនុគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- យោងប្រកាសលេខ ២២៨៩/០៤ ក.អ.ក ចុះថ្ងៃទី១៩ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើត ក្រុមកំណែទំរង់កិច្ចសំរួលពាណិជ្ជកម្ម ។

## <u>សំរេច</u>

**<u>ប្រការ១:</u>** ត្រូវបានបង្កើតគណៈកម្មការ វាយតំលៃ និងជ្រើសរើសសេវាពិគ្រោះយោបល់ ដើម្បីអនុវត្តគំរោងកំណែទំរង់កិច្ចសំរួលពាណិជ្ជកម្ម ដែលមានសមាសភាពដូចខាងក្រោម:

១- ឯកឧត្តម **គឹម ស៊ីថន** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ប្រធានក្រុមកំណែទំរង់កិច្ចសំរួលពាណិជ្ជកម្ម ប្រធាន



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile: (855-23) 426396

២- លោក **លី ផាវណ្ណារ៉ា** អគ្គនាយករងបច្ចេកទេស ក្រសួងពាណិជ្ជកម្ម អនុប្រធាន

៣- លោក **ទ័ត សុគិន** ប្រធាននាយកដ្ឋានគណនេយ្យ ក្រសួងពាណិជ្ជកម្ម សមាជិក

៤- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

៥- លោក **ម៉ែន សុទិជាតិ** អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម សមាជិក

៦- លោក **ឌរ សារី** ជំនួយការឯកឧត្តមទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សមាជិក

**ប្រការ២:** គណៈកម្មការវាយតំលៃ និងជ្រើសរើស សេវាពិគ្រោះយោបល់នេះ មានភារៈកិច្ចដូចតទៅ :

១- ពិនិត្យ និង វាយតំលៃលើសមត្ថភាព និង គុណភាពនៃក្រុមហ៊ុនពិគ្រោះយោបល់ ដែលបានដាក់ពាក្យសុំដេញថ្លៃ ដើម្បីផ្តល់សេវាពិគ្រោះយោបល់នៅក្រសួងពាណិជ្ជកម្ម

២- ជ្រើសរើស និងរៀបចំតាមលំដាប់លេខរៀង នូវក្រុមហ៊ុនផ្តល់សេវាពិគ្រោះយោបល់ទៅតាមមុខជំនាញរបស់ក្រុមហ៊ុននីមួយៗ លើគំរោងការងារទាំង ០៦ ចំណុចដែលរាជរដ្ឋាភិបាលបានប្រកាសរកសេវា ពិគ្រោះយោបល់ គឺ :

- ការពិនិត្យឡើងវិញនូវតួនាទីជាយុទ្ធសាស្ត្ររបស់នាយកដ្ឋានកាំកុងត្រូល
- ការវិភាគអំពីសំណូមពរសំរាប់ការអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិជ្ជាពត៌មាន និង គមនាគមន៍
- ផែនការអភិវឌ្ឍន៍ធនធានមនុស្ស
- ប្រព័ន្ធវាស់ស្ទង់ការអនុវត្តន៍
- ផែនការកសាងសមត្ថភាពនៃការចូលរួមរបស់ផ្នែកឯកជនក្នុងហេដ្ឋារចនាសម្ព័ន្ធ
- ការបង្កើតនូវសៀវភៅណែនាំការអនុវត្តន៍

៣- សហការជាមួយម្ចាស់ជំនួយ ដើម្បីចុះកិច្ចសន្យាជួលក្រុមហ៊ុនទាំងឡាយណាដែលត្រូវបានជ្រើសរើសអោយផ្តល់សេវាពិគ្រោះយោបល់

៤- រាយការណ៍ជូនឯកឧត្តមប្រធានអនុគណៈកម្មការអចិន្ត្រៃយ៍ ទទួលបន្ទុកកំណែទំរង់កិច្ចសំរួលពាណិជ្ជកម្ម នូវឈ្មោះក្រុមហ៊ុនផ្តល់សេវាពិគ្រោះយោបល់ដែលត្រូវបានជ្រើសរើសឱ្យផ្តល់សេវាពិគ្រោះយោបល់តាមជំនាញនីមួយៗ នៃចំណុចទាំង ០៦ ខាងលើ ។

**ប្រការ៣:** គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ជាផ្លូវការនូវត្រារបស់ក្រសួងពាណិជ្ជកម្ម ។



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile: (855-23) 426396

**ប្រការ៤:** អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ នាយិកាខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>ចំលងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- ដូចប្រការ៤ ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile: (855-23) 426396